តុលាការកំពូល

លេខ ១៨៩-៩៤ ត.ក

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីណែនាំ

## ស្តីពី

## ការទទួល និងដាក់សំណុំរឿងជំនុំជម្រះ

**១-អំពីសំណុំរឿងចូលៈ**

សំណុំរឿងទាំងអស់គឺសំណុំរឿងរដ្ឋប្បវេណី រាប់ទាំងសំណុំរឿងវិវាទពាណិជ្ជកម្ម វិវាទការងារ និងវិវាទរដ្ឋបាលផង និងសំណុំរឿងព្រហ្មទណ្ឌ ដែលបញ្ជូនមកពីសាលាឧទ្ធរណ៍ដល់តុលាការកំពូលដោយមានបណ្តឹងសាទុក្ខត្រូវនាយកដ្ឋានសរុប និងត្រួតពិនិត្យជាអ្នកទទួល ។

នាយកដ្ឋាននេះ ក្រោយពីបានពិនិត្យឃើញថា មានលិខិតភ្ជាប់សព្វគ្រប់ និងត្រឹមត្រូវទើបទទួលយកជាពិសេសបណ្តឹងសាទុក្ខ ត្រូវមានហត្ថលេខា អ្នកមានប្រយោជន៍ ឬ អ្នកតំណាងរបស់គេ មានហត្ថលេខាក្រឡាបញ្ជីមានកាលបរិច្ឆេទ ។ បន្ទាប់មកសំណុំរឿង ត្រូវដាក់ជូនប្រធានតុលាការកំពូលពិនិត្យ ។

ក្រោយពីបានពិនិត្យសំណុំរឿងរួចហើយ ឯកឧត្តមប្រធានចារលើសំណុំរឿងនោះបញ្ជូនទៅអោយសភាផ្នែករដ្ឋប្បវេណី ឬ សភាផ្នែកព្រហ្មទណ្ឌ តាមរយៈនាយកដ្ឋានសរុប និងត្រួតពិនិត្យ ដើម្បីចុះលេខរឿង និងបំពេញបែបបទនៃនីតិវិធី ។ ជាបឋមសភារដ្ឋប្បវេណី កោះភាគី ដើមបណ្តឹងសាទុក្ខអោយមកបង់ប្រាក់ក្តី។

ក្រឡាបញ្ជីកាន់ហិបប្រាក់ នៅពេលដែលដើមបណ្តឹងសាទុក្ខចូលមកបង់ប្រាក់ប្រដាប់ក្តីរួចហើយ ត្រូវយកសំណុំរឿងនោះទៅប្រគល់ឱ្យសភាផ្នែករដ្ឋប្បវេណីវិញភ្លាម ។ នៅពេលជាមួយគ្នានោះដែរក្រឡាបញ្ជីត្រូវនាំដើមបណ្តឹងសាទុក្ខអោយទៅជួបសភាផ្នែកនោះ ដើម្បីទទួលយកលិខិតជូនដំណឹងអោយធ្វើសារណាក្នុងរយៈពេល២០ថ្ងៃ

លុះបានទទួលសារណាពីដើមបណ្តឹងសាទុក្ខរួចហើយ សភាផ្នែកត្រូវអញ្ជើញភាគីចុងចម្លើយមកតុលាការដើម្បីប្រគល់សារណារបស់ដើមបណ្តឹងទុក្ខ ហើយបង្គាប់អោយធ្វើសារណាឆ្លើយតបនឹងសារណារបស់ដើមបណ្តឹងសាទុក្ខ នោះវិញក្នុងរយៈពេល២០ថ្ងៃដូចគ្នា។

ក្នុងករណីដែលដើមបណ្តឹងសាទុក្ខទទួលដីកាអោយបង់ប្រាក់ប្រដាប់ក្តីរួចហើយ ប៉ុន្តែមិនព្រមយកប្រាក់មកបង់ក្នុងរយៈពេល ២ខែ នោះតុលាការកំពូលចំណាយរឿងចេញពីបញ្ជី ហើយបង្វិលសំណុំរឿងនិងសាលដីកាអោយសាលាឧទ្ធរណ៍វិញ។ ប៉ុន្តែមានករណីពិសេស ដែលដើមបណ្តឹងសាទុក្ខទីទាល់ក្រហើយបានធ្វើពាក្យសុំអនុគ្រោះឲ្យរួចផុតពីការបង់ប្រដាប់ក្តីនេះ តុលាការកំពូលត្រូវចាត់ការតាមនិតិដូចខាងលើដែរក្រោយពីមានដីកាសម្រេចអនុគ្រោះ

ប៉ុន្តែក្នុងករណីដែលភាគីម្ខាង ឬគូភាគីទាំងសងខាងបានទទួលលិខិតជូនដំណឹងអោយធ្វើសារណារួចហើយ ប៉ុន្តែភាគីម្ខាងនោះ ឬគូភាគីទាំងសងខាងនោះ ពុំព្រមបំពេញបែបបទតាមកាលកំណត់ទេ សភាផ្នែកត្រូវដាក់សំណុំរឿងជូនឯកឧត្តមប្រធានពិនិត្យ ។

ដំណឹងស្តីពីបណ្តឹងសាទុក្ខ ក៏ត្រូវជូនដល់មេធាវី ឬអ្នកការពារជាដាច់ខាតដែរ។ មេធាវី ឬ អ្នកការពារអាចដាក់ការពិនិត្យបណ្តឹងសាទុក្ខនៅការិយាល័យក្រឡាបញ្ជីបាន ក្រោយពេលចុះហត្ថលេខាលើបណ្តឹងសាទុក្ខ ។ ឯសំណុំរឿងត្រូវទុកនៅការិយាល័យក្រឡាបញ្ជីសភាផ្នែក ដើម្បីឱ្យមេធាវីចាត់ការអោយមកចម្លងតាមត្រូវការ ។ ទម្រង់បែបបទនេះត្រូវតែធ្វើខានមិនបាន ក្នុងករណីដែលភាគីទាំងសងខាងបានបំពេញបែបបទដូចចែងខាងលើនេះសព្វគ្រប់

អស់ហើយ សភាផ្នែកត្រូវបញ្ជូនសំណុំរឿង នោះទៅឯកឧត្តមប្រធានតុលាការកំពូល។ ឯកឧត្តមប្រធានក្រោមពីបាន ពិនិត្យឃើញថា គូភាគីទាំងសងខាងបានបំពេញតាមទម្រង់បែបបទសព្វគ្រប់ហើយ ទើបធ្វើដីកាចាត់តាំងមួយប្រគល់ សំណុំរឿងឱ្យទៅចៅក្រមណាម្នាក់ធ្វើរបាយការណ៍ និងសន្និដ្ឋានវាយតម្លៃលើទម្រង់ និងគតិច្បាប់ ព្រមទាំងលើក គោលការណ៍អង្គច្បាប់ ដែលត្រូវដោះស្រាយ និយាយរួមរបាយការណ៍ត្រូវគោរពតាមមាត្រា ២១៥ នៃច្បាប់ស្តីពីនីតិ វិធីព្រហ្មទណ្ឌ ។ ចៅក្រមរបាយការណ៍ ត្រូវដាក់របាយការណ៍នោះជូនឯកឧត្តមប្រធានពិនិត្យជាសំងាត់ហើយត្រូវ ដាក់ចូលជាឧបសម្ព័ន្ធក្នុងសំណុំរឿង ដែលត្រូវបញ្ជូន ទៅអង្គព្រះរាជអាជ្ញា ដើម្បីធ្វើការសន្និដ្ឋាន ។ ប៉ុន្តែមុននឹងបញ្ជូន ទៅអគ្គព្រះរាជអាជ្ញា សំណុំរឿងរដ្ឋប្បវេណី ត្រូវបានក្រឡាបញ្ជីចុះក្នុងសៀវភៅដាក់រឿងជំនុំជម្រះសម្រាប់សវនាការ នាពេលខាងមុខ ដែលប្រធានបានកំណត់ទុករួចហើយ ។ ក្រោយពីបានពិនិត្យសំណុំរឿងរួចហើយអគ្គព្រះរាជអាជ្ញា បញ្ជូនសំណុំរឿងនោះមកប្រធានតុលាការកំពូលវិញ ។ ជាគោលការណ៍តុលាការកំពូល ត្រូវជំនុំជម្រះក្នុងរយៈវេលា ៣ខែ យ៉ាងយូរគិតពីរថ្ងៃទទួលសំណុំរឿង និងឯកសារសំអាងនៅការិយាល័យក្រឡាបញ្ជីតុលាការកំពូល ។

ចំពោះរឿងព្រហ្មទណ្ឌក៏ត្រូវអនុវត្តបែបបទដូចគ្នាដែរ ។ក៏ប៉ុន្តែសំណុំរឿងព្រហ្មទណ្ឌគ្មានការបង់ប្រាក់ក្តីទេ ។ សំណុំរឿងប្រភេទនេះ បន្ទាប់ពីចាត់ការតាមនីតិវិធីរួចហើយ សភាផ្នែក ត្រូវជូនឯកឧត្តមប្រធានពិនិត្យ ។ លុះពិនិត្យ ទៅឃើញថា ត្រឹមត្រូវតាមបែបបទអស់ហើយ ឯកឧត្តមប្រធានត្រូវចាត់តាំងចៅក្រមម្នាក់អោយធ្វើរបាយការណ៍ដូច រឿងរដ្ឋប្បវេណីដែរ រួចហើយទើបបញ្ជូនទៅមហាអយ្យការអមតុលាការកំពូលពិនិត្យ និងសន្និដ្ឋាដើម្បីកោរជំនុំជម្រះ តាមកាលបរិច្ឆេទ ដែលបានការឯកភាពជាមួយឯកឧត្តមប្រធានតុលាការកំពូល ។

**២-អំពីចំណាត់ការកោះគូភាគីឬជនជាប់ចោទមកធ្វើសវនាការៈ**

ចំពោះរឿងរដ្ឋប្បវេណីគឺសុភាផ្នែកនេះជាអ្នកចាត់ការកោះគូភាគីទាំងសងខាង និងមេធាវីអ្នកការពារក្តីអោយ ចូលមកធ្វើសវនាការ និងការពារកូនក្តីតាមការបរិច្ឆេទដែលកំណត់ឡើងដោយឯកឧត្តមប្រធាន ។ ឯដីកាកោត្រូវចុះ ហត្ថលេខា ដោយឯកឧត្តមប្រធានតុលាការកំពូល ។

ចំពោះរឿងព្រហ្មទណ្ឌ គឺមហាអយ្យការអមតុលាការកំពូល ជាអ្នកកោះគូភាគីទាំងសងខាងជាអ្នកធ្វើដីកានាំ យកទណ្ឌិតចេញពីពន្ធនាគារមកជំនុំជម្រះ និងលិខិតអញ្ជើញមេធាវី ឬអ្នកការពារក្តី តាមកាលបរិច្ឆេទ ដែលបានឯក ភាពជាមួយឯកឧត្តមប្រធានតុលាការកំពូល មហាអយ្យការដោះលែងជនជាប់ចោទដែលតុលាការកំពូលសម្រេចឱ្យ រួចខ្លួនឬទណ្ឌិតដែលបានទទួលរងទោសគ្រប់ចំនួនតាមការកំណត់។ ក្នុងករណីសំណុំរឿងស្ថិតនៅតុលាការកំពូល ។

**៣-អំពីការងារចាត់តាំងធ្វើសវនាការជំនុំជំរះលើកទី១ៈ**

មុនពេលបើកឱកាសធ្វើសវនាការជំនុំជម្រះរឿងក្តី ប្រធានតុលាការកំពូលត្រូវធ្វើដីកាចាត់តាំងចៅក្រម សម្រាប់ជំនុំជម្រះចំនួន ៥ រូប រួមទាំងប្រធាន និងចៅក្រមបម្រុង។ ការជំនុំជម្រះរបស់តុលាការកំពូលលើកទី១ គឺ សម្រេចតែពីអង្គច្បាប់ ប៉ុណ្ណោះពុំសម្រេចពីអង្គហេតុទេ ។

ទន្ទឹមពេលនេះដែរ សភាផ្នែកត្រូវចាត់តាំងក្រឡាបញ្ជីមួយនាក់ឱ្យចូលរួមក្នុងសវនាការ ។ ត្រូវមានតំណាង មហាអយ្យការ ១ នាក់ ទៀតចូលរួមក្នុងសវនាការជំនុំជម្រះ ។ ចំពោះប្រតិទិនបើកសវនាការ គឺសប្តាហ៍នីមួយៗត្រូវ បែងចែកយកថ្ងៃណាខ្លះសម្រាប់ជំនុំជម្រះ ហើយថ្ងៃណាសម្រាប់ជំនុំជម្រះរឿងរដ្ឋប្បវេណី ថ្ងៃណាសម្រាប់ជំនុំជម្រះ រឿងព្រហ្មទណ្ឌ ។

<u>អំពីការពិនិត្យ ការសិក្សាសំណុំរឿងមុនពេលសវនាការ</u>

ក្រោយពីបានពិនិត្យ និងសន្និដ្ឋានរួចហើយ អគ្គព្រះរាជអាជ្ញាត្រូវបង្វែរសំណុំរឿងទាំងអស់ទៅប្រធានតុលាការ កំពូលវិញ ឱ្យបានមុនថ្ងៃជំនុំជម្រះ យ៉ាងយឺតណាស់ក៏មួយសប្តាហ៍ដែរ ប្រធានតុលាការកំពូលត្រូវជូនសំណុំរឿងទៅ គ្រប់ចៅក្រម ដែលត្រូវចាត់តាំងឱ្យជំនុំជម្រះឱ្យពិនិត្យសិក្សាកត់ត្រាទុកចំណុចសំខាន់ៗ សម្រាប់ពេលជំនុំជម្រះក្នុង នេះក៏ទាមទារពេលវេលាឱ្យគ្រប់គ្រាន់ដែរ ។

លុះចៅក្រមបានពិនិត្យសំណុំរឿងគ្រប់គ្នាហើយ ទើបសភាផ្ទេកបញ្ជូនសំណុំរឿងទៅប្រធានពិនិត្យជាចុងក្រោយរហូតថ្ងៃជំនុំជម្រះ ។

**<u>៤-ពីការជំនុំជម្រះរួមក្រុម លើបណ្តឹងសាទុក្ខលើកទី II</u>**

ក្នុងការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី២ តុលាការកំពូលត្រួតពិនិត្យទាំងអង្គហេតុទាំងអង្គច្បាប់ឡើងវិញ។ ក្នុងករណីដែលតុលាការសម្រេចបដិសេធសាលដីកាសាលាឧទ្ធរណ៍ ហើយបង្វិលទៅឱ្យសាលានោះសម្រេចឡើងវិញ តុលាការកំពូល ត្រូវចង្អុលប្រាប់ចំណុចដែលអោយសម្រេចនោះអោយបានច្បាស់លាស់ ។ ករណីនោះបើសាលាឧទ្ធរណ៍ ពុំឯភាពលើចំណុចដែលតុលាការកំពូលឱ្យសម្រេចនោះទេនោះភាគីអាចប្តឹងសាទុក្ខជាលើកទី២ មកតុលាការកំពូលវិញ ។

តុលាការកំពូលត្រូវបើកសវនាកាជំនុំជម្រះជាលើកទី២ ដោយមានសមាសភាពចៅក្រមចូលរួមចំនួន ៩ រូប រួមទាំងប្រធានផង។ ឯនីតិវិធីកោជំនុំជម្រះត្រូវអនុវត្តដូចលើកមុន។

ប៉ុន្តែមុនបើកសវនាការជំនុំជម្រះរួមក្រុមនេះ តុលាការកំពូលត្រួតពិនិត្យសំណុំរឿងអោយបានត្រឹមត្រូវនឹងហ្មត់ចត់ ។ បើពិនិត្យទៅឃើញថា នៅមានកង្វះខាតនោះប្រធានតុលាការកំពូលត្រូវចាត់តាំងចៅក្រមម្នាក់ឱ្យស៊ើបអង្កេតបន្ថែម ឬឱ្យអ្នកជំនាញផ្តល់ព័ត៌មានឱ្យបានសព្វគ្រប់ ឬ ឱ្យធ្វើកោសល្យវិច័យ ឬប្រតិកោសល្យវិច័យ ។

ក្រោយពីតុលាការកំពូលសម្រេចរួមក្រុមជាស្ថាពរហើយ គូក្តីពុំមានសិទ្ធិប្តឹងតវ៉ាទៀតឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩៤

**ប្រធានតុលាការកំពូល**

**ចែម សួន**

<u>ចម្លងជូន</u>

-មហាអយ្យការអមតុលាការកំពូល

-ដើម្បីជ្រាប